ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ អនក្រ.សស

# សេចក្តីសម្រេច

ស្តីពី

ការចាត់តាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ
ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទាន
ដល់ការរីកសាយភាយអាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៦០ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## សម្រេច

**ប្រការ ១.-**

ចាត់តាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ហៅកាត់ថា **គ.ស.ហ.** ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- **សម្តេចក្រឡាហោម ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម **ជា ចាន់តូ** | អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **ខឹ ច័ន្ទផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **ខឹវ សុខហាក់** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥- ឯកឧត្តម **រស់ សីលវ៉ា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ញឹម ខេមរា** | រដ្ឋលេខាធិការក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧- ឯកឧត្តម នាយឧត្តមសេនីយ៍ **សាវ សុខ** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨- ឯកឧត្តម **សុខ សុភ័ក្ត្រ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- ឯកឧត្តម **ស៊ុំ សន្និសិទ្ធ** | ប្រធានក្រុមប្រឹក្សាភិបាលនៃ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | សមាជិក |
| ១០- ឯកឧត្តម **ទ្រី ត្រាយ** | អនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប្រឆាំងអំពើភេរវកម្ម | សមាជិក |
| ១១- ឯកឧត្តម **រិទ្ធ អារុណាទិត្យា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសម្របសម្រួល កិច្ចការផ្ទៃក្នុង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២- លោក **អ៊ុំ សុផល** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៣- លោកជំទាវ **សាយ សំអាត** | ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | លេខាធិការ។ |

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣ រោចខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ